ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

លេខ : ០០៧/១៧ សណន.ច

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៧

# សេចក្ដីណែនាំ
## ស្ដីពី
## ការដោះស្រាយចរាចរណ៍ និងរៀបចំសណ្ដាប់ធ្នាប់តាមដងផ្លូវ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

ក្នុងរយៈពេលកន្លងមកនេះ រដ្ឋបាលរាជធានីភ្នំពេញពិនិត្យឃើញថា បងប្អូនប្រជាពលរដ្ឋមួយចំនួនដែលជាម្ចាស់លំនៅដ្ឋាន ម្ចាស់សហគ្រាស ម្ចាស់ហាង ម្ចាស់អាជីវកម្ម មន្ទីរពេទ្យ សាលារៀន ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជនផ្សេងទៀត បាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងជាយផ្លូវមិនទាន់បានសមស្របទាំងស្រុង ឬដោយបំពានលើបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសបំពានលើបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្ដីពីផ្លូវថ្នល់ ច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយកម្ម និងសំណង់។ អំពើរំលោភបំពានទាំងនោះមានជាអាទិ៍ ការយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងជាយផ្លូវធ្វើជាចំណតយានជំនិះ ការតសំយ៉ាប ការហ៊ុំព័ទ្ធយកចិញ្ចើមផ្លូវ ការយកផ្លូវធ្វើជើងឬចិញ្ចើមផ្លូវធ្វើទីតាំងការដ្ឋានទុកដាក់សម្ភារៈ ឬដាក់តាំងបង្ហាញទំនិញ ឬប្រកបអាជីវកម្ម ផ្សេងៗជាលក្ខណៈឯកជន ដែលបង្កឱ្យមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្ដាប់ធ្នាប់សាធារណៈ និងសោភណភាពរាជធានីភ្នំពេញ។

អនុវត្តតាមស្មារតីនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ រដ្ឋបាលរាជធានីភ្នំពេញសម្រេចជ្រើសយកផ្លូវសំខាន់ៗចំនួន ១១ខ្សែ ធ្វើជាអាទិភាពគំរូ សម្រាប់អនុវត្តវិធានការដោះស្រាយចរាចរណ៍ និងរៀបចំសណ្ដាប់ធ្នាប់សាធារណៈ មុននឹងបន្តអនុវត្តចំពោះបណ្ដាទីតាំងផ្សេងៗទៀតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ផ្លូវអាទិភាពគំរូទាំងនោះរួមមាន៖ ១- មហាវិថីសហព័ន្ធរុស្ស៊ី, ២- មហាវិថីព្រះមុនីវង្ស, ៣- មហាវិថីកម្ពុជាក្រោម, ៤- មហាវិថីម៉ៅសេទុង, ៥- មហាវិថីព្រះសីហនុ និងមហាវិថីនេរូ, ៦- មហាវិថីព្រះនរោត្តម, ៧- មហាវិថីសម្ដេចមុនីរ៉េត, ៨- ផ្លូវឧកញ៉ាទេពផន, ៩- មហាវិថីហ្សាលនីហ្គោល, ១០- មហាវិថីយោធពលខេមរភូមិន្ទ (ផ្លូវ២៧១) និងផ្លូវឧកញ៉ាឃ្លាំងមឿង (ផ្លូវលេខ៧០) និង ១១- តីរវិថីព្រះស៊ីសុវត្ថិ។

ដូចនេះ ដើម្បីដោះស្រាយចរាចរណ៍ និងរៀបចំសណ្ដាប់ធ្នាប់តាមដងផ្លូវអាទិភាពខាងលើ រដ្ឋបាលរាជធានីភ្នំពេញ ដាក់ចេញនូវសេចក្ដីណែនាំដូចខាងក្រោម៖

**ក. ចំពោះបងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន មន្ទីរពេទ្យ សាលារៀន វិស័យឯកជន អគារសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវអនុវត្តដូចខាងក្រោម៖**

១. ហាមចតយានយន្តគ្រប់ប្រភេទនៅលើទ្រូងផ្លូវ។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

២. ហាមដាច់ខាតមិនឱ្យម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុំមព័ទ្ធការដ្ឋានលើចិញ្ចើមផ្លូវ លើសពី១/៣ (មួយភាគបី) និងឬប្រើប្រាស់ទ្រូងផ្លូវដើម្បីទុកដាក់សម្ភារៈសំណង់របស់ខ្លួន ដូចជា ដែក ខ្សាច់ គ្រួស ថ្ម ជាដើម។

៣. រថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ ត្រូវចេញ-ចូល គោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងចៀសវាងការប្រើប្រាស់ទ្រូងផ្លូវ ក្នុងការលើកដាក់ ផ្ទេរទំនិញ និងបាញ់បេតុង។ ក្នុងករណីចៀសវាងមិនបាន ត្រូវអនុវត្តការលើកដាក់ទំនិញ និងការបាញ់បេតុង ចាប់ពីម៉ោង២១:០០នាទី រហូតដល់ម៉ោង០៦:០០នាទីព្រឹក។

៤. ការរៀបចំសម្ភារៈ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ អាចប្រើប្រាស់ចំណែកចិញ្ចើមផ្លូវត្រឹម ១/៣ (មួយភាគបី) ជាលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយទុក២/៣ (ពីរភាគបី) សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្តាប់ធ្នាប់ និងចរាចរណ៍។

៥. រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ ម៉ូតូ មិនត្រូវឱ្យលើសពី១/៣ (មួយភាគបី) ឡើយ។

**ខ. ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ត្រូវអនុវត្តដូចខាងក្រោម៖**

១. ត្រូវចុះធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋ ដែលបាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ ដោយរំលោភបំពាន ដោយប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់ តែម៉ឺងម៉ាត់ ឱ្យចូលរួមអនុវត្តតាមស្មារតីនៃសេចក្តីណែនាំនេះ។ ក្នុងករណីនៅតែមិនអនុវត្តតាមការណែនាំនេះ មន្ត្រីអនុវត្តត្រូវធ្វើកំណត់ហេតុ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

២. ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន និងម្ចាស់ទីតាំងអាជីវកម្មនានាឱ្យគោរពតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ក្នុងករណីពុំព្រមអនុវត្តតាម អាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅបិទទីតាំងអាជីវកម្ម។

៣. ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ក្នុងករណីមិនរាងចាល ត្រូវផ្អាកការដ្ឋាននោះភ្លាម។

៤. ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ និងត្រូវមានវិធានការឱ្យបានម៉ឺងម៉ាត់ក្នុងករណីការចេញ-ចូលរាជធានីភ្នំពេញខុសពីសេចក្តីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។

៥. ត្រូវអនុវត្តការងារតាមការណែនាំខាងលើនេះ ឱ្យបានត្រឹមត្រូវ ហ្មត់ចត់ និងទន់ភ្លន់ និងត្រូវរាយការណ៍ប្រចាំសប្តាហ៍អំពីលទ្ធផលនៃការងារនេះ មកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

**គ. ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញត្រូវ៖**

១. បន្ថែមកម្លាំងនគរបាលចរាចរណ៍ ដោះស្រាយបញ្ហាចរាចរណ៍តាមគោលដៅដែលមានការកកស្ទះ នៅចន្លោះម៉ោងមមាញឹក គឺម៉ោង ០៧:៣០នាទី ដល់ម៉ោង ០៨:៣០នាទី, ម៉ោង ១១:៣០នាទី ដល់ម៉ោង ១២:៣០នាទី និងម៉ោង ១៧:០០នាទី ដល់ម៉ោង ១៨:៣០នាទី។

២. រៀបចំរថយន្តស្ទូច ដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ដើម្បីអនុវត្តវិធានការច្បាប់។


៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ទទួលបានសេចក្តីណែនាំនេះ ប្រជាពលរដ្ឋ គ្រឹះស្ថានឯកជន ស្ថាប័នសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវ មានរយៈពេល ០២ (ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ ដើម្បីធ្វើការកែសម្រួល និងរៀបចំទីតាំងរបស់ខ្លួនឱ្យស្របតាមស្មារតីនៃសេចក្តីណែនាំនេះ។

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១២ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បងប្អូនប្រជាពលរដ្ឋ អ្នកប្រើប្រាស់ផ្លូវទាំងអស់ត្រូវរួមអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន

  "ដើម្បីជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង ១២
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ

  "ដើម្បីមុខការ"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ